ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ០៦២ គ.ឃ.ស

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតប្រពន្ធ័គាំទ្រដល់ការកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ក្នុងខេត្ត ក្រុងចំនួន៧

( ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកណ្តាល ខេត្តកោះកុង ខេត្តស្ទឹងត្រែង ខេត្តបណ្តាយមានជ័យ).

### ១.សេចក្តីផ្តើម

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ទាមទារអោយក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំ អនុម័ត និង អនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ សំរាប់រយៈពេល ៥ ឆ្នាំ ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំ និងអនុម័តនៅក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ក្រុមប្រឹក្សា ហើយនឹងត្រូវពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវស្របទៅនឹងផែនការជាតិស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ។ ប្រកាសអន្តរក្រសួងស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ មានចែងលំអិតអំពីដំណើរការ ដំណាក់កាល និង ជំហានចាំបាច់ ដែលត្រូវអនុវត្តនៅក្នុងពេលកសាងផែនការ ។ ដូច្នេះផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំ និង អនុម័ត ហើយត្រូវបានធ្វើអនុលោមភាពដោយអភិបាលខេត្ត ក្រុង គឺជាល័ក្ខខ័ណ្ឌចាំបាច់សំរាប់ធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានលទ្ធភាពទទួលបានថវិកាវិភាជន៍ផ្នែកអភិវឌ្ឍន៍ពីរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ។

បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រសួងពាក់ព័ន្ធផ្សេងទៀតកំពុងផ្តល់សេវា និង ការគាំទ្រផ្សេងៗដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

កន្លងមកនេះអង្គភាពរដ្ឋបាលមូលដ្ឋានប្រចាំខេត្ត ក្រុងក៏បានបង្កើតឡើងគ្រប់ខេត្ត ក្រុងទាំងអស់ អង្គភាពនេះគឺជា យន្តការទំនាក់ទំនងរវាងក្រសួងថ្នាក់ជាតិ ជាមួយអភិបាលខេត្ត ក្រុង និង ក្រុមប្រឹក្សាឃុំ សង្កាត់ ។ លើសពីនេះទៅទៀត ការបណ្តុះបណ្តាលចំនួនបីវគ្គដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវបានបញ្ចប់ ។ ឆ្លងតាមការបណ្តុះបណ្តាលនេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ទទួលបាននូវសមត្ថភាពមួយចំនួនដើម្បីបំពេញតួនាទី និង មុខងាររបស់ខ្លួន ។

២_បញ្ហាលំបាកចំពោះមុខ :

ទោះបីជាយើងបានរៀបចំប្រព័ន្ធគាំទ្រទំនាក់ទំនង និង បានពង្រឹងសមត្ថភាពមួយចំនួនដល់ក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងណាក្តី ក៏នៅមានបញ្ហាលំបាកចំពោះមុខដូចខាងក្រោម ÷

• មន្ត្រីរដ្ឋបាលមូលដ្ឋានប្រចាំខេត្ត ក្រុងមានភាពខុសគ្នារវាងខេត្ត ក្រុងដែលមានការគាំទ្រពីកម្មវិធីសិលាជាមួយនឹង ខេត្ត ក្រុងដែលគ្មានការគាំទ្រពីកម្មវិធីនេះ ។

• សេវាគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីកសាងផែនការអភិវឌ្ឍន៍ ក៏មានភាពខុសគ្នារវាងខេត្ត ក្រុងដែលមានការគាំទ្រពីកម្មវិធីសិលា ជាមួយនឹងខេត្ត ក្រុងដែលគ្មានការគាំទ្រ ។ បណ្តាខេត្ត ក្រុងដែលមានការគាំទ្រពីកម្មវិធីសិលា មានប្រព័ន្ធគាំទ្រថ្នាក់ខេត្ត និង ថ្នាក់ស្រុក ( អ្នកសំរបសំរួលថ្នាក់ខេត្ត និង ស្រុក ) រីឯនៅតាមបណ្តាខេត្ត ក្រុង ដែលគ្មានការគាំទ្រពីកម្មវិធីសិលាមិនមានប្រព័ន្ធគាំទ្រនេះឡើយ ។

• ក្រុមប្រឹក្សាឃុំ សង្កាត់ដែលគ្មានការគាំទ្រពីកម្មវិធីសិលា (គ្មានអ្នកសម្របសម្រួលថ្នាក់ខេត្ត ស្រុក) ពុំអាចមានសមត្ថភាព និង បទពិសោធន៍គ្រប់គ្រាន់ក្នុងការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន ការគៀងគរធនធាន ទ្រព្យសម្បត្តិ និង ការអភិវឌ្ឍន៍អភិបាលកិច្ចល្អបាននៅឡើយ ។

• ដំណើរការកសាងផែនការអភិវឌ្ឍន៍នៅតាមតំបន់ទីក្រុង ទីប្រជុំជន មានការលំបាកក្នុងការរៀបចំផែនការក្នុងករណី គ្មានបទពិសោធន៍ និង គ្មានប្រព័ន្ធគាំទ្រ ។

• ពុំអាចមានយន្តការសំរាប់កំណត់នូវគំលាតរវាងឃុំ សង្កាត់ ដែលដំណើរការបានលឿន ហើយល្អ និង ឃុំ សង្កាត់ ដែលមានដំណើរការយឺត ។

• ខេត្ត ក្រុងដែលមិនមានការគាំទ្រពីកម្មវិធីសិលា ធ្វើអោយវត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាល និង ទីភ្នាក់ងារ អភិវឌ្ឍន៍ខាងក្រៅមានចំនួនតិចតួច ។

៣_ផលវិបាកដែលអាចកើតឡើង ក្នុងករណីគ្មានដំណោះស្រាយ

• គំលាត និង វិសមភាពកាន់តែធំនៅក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ និង នាំអោយមានឥទ្ធិពលអវិជ្ជមានមក លើទិសដៅវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

• ឃុំ សង្កាត់ ដែលទន់ខ្សោយ គ្មានលទ្ធភាពឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងការកសាងផែនការដែលកំណត់ដោយប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។ បញ្ហានេះធ្វើអោយមានការពន្យាពេលបន្ថែមទៀត ដើម្បីទទួលបានធនធានពីមូលនិធិឃុំ សង្កាត់ ឬ គ្មានលទ្ធភាពប្រើប្រាស់ធនធាននេះ ដែលនឹងនាំអោយមានអតុល្យភាពនៅក្នុងការអភិវឌ្ឍន៍ និង ការផ្តល់សេវា ។

៤_ដំណោះស្រាយ

ដើម្បីដោះស្រាយបញ្ហាលំបាកចំពោះមុខខាងលើនេះ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រសួងស្ថាប័ពាក់ព័ន្ធ អភិបាលខេត្ត ក្រុងទាំង ៧ អនុវត្តនូវវិធានការដូចខាងក្រោម ÷

ក-ក្របខណ្ឌពេលវេលានៃជំហានទាំងឡាយក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ពេលវេលានៃជំហានទាំងឡាយក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវមានភាពបត់បែន ដើម្បីអនុញ្ញាតអោយឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុងទាំង៧ បញ្ចប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ខ្លួនអោយបានមុន *ខែ កុម្ភៈ ឆ្នាំ ២០០៣* អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ចំពោះកិច្ចដំណើរការនៅតាមដំណាក់កាល និង ជំហាននានាដែលបានកំណត់ក្នុងសេចក្តីណែនាំអំពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏ត្រូវមានភាពបត់បែន និង ច្នៃប្រឌិតអោយបានសមស្របតាមចំណុចពិសេសរបស់ឃុំ សង្កាត់ ដែលស្ថិតក្នុងតំបន់ផ្សេងៗគ្នា ដូចជា ឃុំ សង្កាត់ក្នុងតំបន់ទីក្រុង ទីប្រជុំជន ឃុំស្ថិតក្នុងតំបន់ខ្ពង់រាប . . . ។ល។

ខ-អំពីការរៀបចំក្រុមគាំទ្រក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

កន្លងមកយើងបានបណ្តុះបណ្តាលគ្រូឧទ្ទេសចំនួន *៦៧ នាក់* នៅក្នុងខេត្ត ក្រុងទាំង៧ ។ ក្រៅពីនេះក៏មានមន្ត្រី នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋានចំនួន *២៣នាក់* ក៏បានទទួលការបណ្តុះបណ្តាលជាគ្រូឧទ្ទេសផងដែរ ធនធានទាំងនេះនឹងអាចផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងដំណើរការកសាងផែនការ សំរាប់ឃុំ សង្កាត់ចំនួន ៣៣៨ ។

ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ អភិបាលខេត្ត ក្រុងទាំង៧ ត្រូវរៀបចំក្រុមគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយផ្អែកលើចំនួនឃុំ សង្កាត់ ដែលមានក្នុងខេត្ត ក្រុងនីមួយៗ ។

ក្នុងការរៀបចំក្រុមគាំទ្រខាងលើនេះ ខេត្ត ក្រុងនីមួយៗត្រូវប្រើប្រាស់គ្រូឧទ្ទេសដែលបានបណ្តុះ-បណ្តាលកន្លងមកដោយប្រគល់ភារកិច្ចនេះ អោយគ្រូឧទ្ទេសម្នាក់សហការជាមួយមន្ទីរផែនការ និង មន្ទីរដែលមានការពាក់ព័ន្ធនានា ទទួលខុសត្រូវគាំទ្រ ឃុំ សង្កាត់ចំនួន៣ ដោយរៀបចំជាក្រុមៗតាមស្រុក ខណ្ឌ នីមួយៗ ចំណុះខេត្តក្រុងរបស់ខ្លួន ។ ក្នុងការរៀបចំក្រុមគាំទ្រនេះ ប្រសិនបើខេត្ត ក្រុងមានការខ្វះខាតគ្រូឧទ្ទេសត្រូវធ្វើការទំនាក់ទំនងជាបន្ទាន់ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ ដើម្បីពិគ្រោះយោបល់ជាមួយអនុគណៈកម្មការផែនការ និង អភិវឌ្ឍន៍ឃុំ សង្កាត់ធ្វើការសំរបសំរួលដោះស្រាយ ។

ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួលក្នុងការបំពេញការងាររបស់ក្រុមគាំទ្រឃុំ សង្កាត់ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួងផែនការ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និង ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដោយមាននាយកដ្ឋានរដ្ឋបាលមូលដ្ឋានជាសេនាធិការ ដើម្បីរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព ជំនាញ បច្ចេកទេស និង វិធីសាស្ត្រសំរបសំរួលបន្ថែមទៀតដល់គ្រូឧទ្ទេស ដែលបានរៀបចំជាក្រុម ចុះជួយគាំទ្រដល់ឃុំ សង្កាត់ ។

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រសួង ស្ថាប័ន ពាក់ព័ន្ធខាងលើ និង អភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធត្រូវខិតខំជួយដល់ក្រុមគាំទ្រ ដើម្បីគាំទ្រអោយឃុំ សង្កាត់មានសមត្ថភាពប្រហាក់ប្រហែលគ្នាក្នុងការកសាងផែនការអភិវឌ្ឍន៍តាមឃុំ សង្កាត់នីមួយៗ ។

### ៥_ រយៈពេលអនុវត្តគំរោង ៖

ដើម្បីធានាអនុវត្តការងារអោយបានទាន់ពេលវេលាការងារគាំទ្រនេះ ត្រូវចាប់ផ្តើមអោយបានឆាប់រហ័ស គឺត្រូវចាប់ផ្តើមពីខែ សីហា ឆ្នាំ ២០០២ នេះ រហូតដល់ឃុំ សង្កាត់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនបានរួចរាល់ជាស្ថាពរ ។

### ៦_ អំពីការគាំទ្រគំរោង

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អនុញ្ញាតអោយកម្មវិធីអភិវឌ្ឍន៍ នៃអង្គការសហប្រជាជាតិ (UNDP) ក្រោមគំរោងគាំទ្រវិមជ្ឈការ (Decentralization support Project) ជាអ្នកជួយគាំទ្រគំរោងកម្មវិធីនេះក្នុងខេត្ត ក្រុងទាំង៧ ដែលមានឃុំ សង្កាត់ចំនួន ៣៣៨ ឃុំ សង្កាត់ ដោយមានកិច្ចសហប្រតិបត្តិការដោយផ្ទាល់ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ និង ការសំរបសំរួលជាមួយក្រសួង ស្ថាប័ន និង កម្មវិធីពាក់ព័ន្ធនានា ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្វាគមន៍ និង សូមអំពាវនាវដល់បណ្តាអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ កម្មវិធីនានា បណ្តាប្រទេសអ្នកផ្តល់ជំនួយ សូមជួយគាំទ្របន្ថែមទៀតដល់កម្មវិធីនេះ ។

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដោយមានកិច្ចសហការពីអភិបាលខេត្ត ក្រុងត្រូវធ្វើសហប្រតិបត្តិការអោយបានជិតស្និទ្ធល្អ ជាមួយគំរោងគាំទ្រវិមជ្ឈការដែលឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍ នៃអង្គការសហប្រជាជាតិ ដើម្បីគៀងគរការចូលរួមឧបត្ថម្ភដល់កម្មវិធីនេះ ។

សេចក្តីសំរេចនេះបានអនុម័តក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់លើកទី ១៥ នាថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២

ច.ត គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

ស ខេង

ឧប-នាយករដ្ឋមន្ត្រី

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងដែលជាសមាជិកគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ
- អង្គការ GTZ
- មូលនិធិខុនរ៉ាដ-អាដិនណៅអ៊ែរ
  "ដើម្បីជូនជ្រាប និង សហការ"
- អគ្គនាយករដ្ឋបាល
- ប្រតិភូរាជរដ្ឋាភិបាល និង គ្រប់អភិបាលខេត្ត ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ